# ប្រជុំពាក្យកាព្យ

## រក្សភិរម្យ (អួង)

## ភាគទី ៤

រៀបរៀងដោយ

**ហៀន~ វិចិត្រ**

ព.ស ២៥៦០

# ពាក្យកាព្យភាគទី ៤

១ សន្ធិយានាក្នុងថ្ងៃអាទិត្យ ចួបជិតមិត្រមូលចូលជីវ័ន
ឃើញភ័ក្ត្រហាក់បានក្សាន្តចិត្តគ្រាន់ លុះចួបថ្ងៃចន្ទ្របាត់ទៅទៀត ។
និតនៅខ្លោចផ្សាឱរាណែន ហាក់ប្រាសមួយសែនកាល្ប៍ចង្អៀត
ថាបើមិនជឿស្បថជូនទៀត ចូរឆ្មៀតមើលចុះឆ្លុះថ្លើមបង ។
នឹកម្តងចិត្តចង់ឃាត់ឱ្យនៅ គិតទៅក្រែងកើតសេចក្តីហ្មង
គេដឹងនិន្ទាដល់ខ្លួនបង នួនល្អងនឹងព្រួយតែដោយសារ ។
ប្អូនអើយថ្លើមបងសៅហ្មងណាស់ ដូចដឹងជាក់ច្បាស់ក្នុងឱរា
នែបនិត្យជិតអូនពេលាណា កក់ក្តៅឱរាថ្លាដូចទឹក ។
រំពេចប្រែប្រាសពីទ្រូងទៅ ឱរាផ្សាក្តៅសែនរឮក
សន្ទែមមែមមាញឹក រឮកនឹងស្តាយឆ្ងាយមេត្រី ។
សន្ធិយារាត្រីខាងរនោច ព្រះចន្ទ្រពីររោចអន់រស្មី
ដូចរៀមឃ្លាតខ្លីមខ្លួនស្រស់ស្រី សេចក្តីគួរគិតឱ្យអនិច្ចំ ។
តែនឹករឮកឡើងកាលណា ចិន្តាសែនខ្វល់អំពល់ខ្លាំង
លុះជិតព្រះចន្ទ្រដើរបិទបាំង បងភាំងភ្លេចខ្លួនចូនធ្វេសលក់ ។

លុះយូរបន្តិចបែរប្រែខ្លួន　　គិតស្មានប្អូនស្ងួនន្ងួននៅមុខ
ប្រវ៉ាឱនឱបក្រសោបទុក　　បើកនេត្រមើលមុខឃើញតែខ្មៅយ ។
ឱយើងទាំងពីរធ្លាប់តែជិត　　តែងនៃបស្មាលស្និទ្ធជិតក្បៀកកើយ
បើបានឃើញភក្ត្រកាលណាហើយ　កែវអើយបងមហាចិន្តាព្រើស ។
នៃបនិត្យជិតស្ងួនពេលាណា　　ប្រាយប្រាប់កិច្ចការមិនឱ្យលើស
រចនាវោហារមិនមានផ្តើស　　ឱ្យល្មើសលើសលស់ខុសចិន្តា ។
សេចក្តីនេះដល់និមិលមិត្ត　　ដ្បិតរៀមព្រួយចិត្តណាស់ធីតា
ពីដួចបែកមកពេលាណា　　ឱវាស្មើរប្រេះរបេះចេញ ។
រំជំរំជួលជ្រួលសព្វសាច់　　ហាក់គេច្របាច់ឈ្លេចញុំញី
មានតែទីទុក្ខទីអំម្មេញ　　ជ្រក់ជ្រេញស្រពន់ទន់កាយា ។
ធុំក្លិនក្រអូបនៅថ្មី ៗ　　ហាក់ថ្លៃនៅនិត្យជិតឱរ៉ា
ភ្ញាឡើងលោលើកនៃហត្ថា　　ប្រវ៉ារកបាត់ស្វាត់ពុំយល់ ។
មានតែទឹកភ្នែកសង្វេគជ្បើយ　កាលណានឹងស្បើយទុក្ខសែនសល់
ឱម្ល៉េះសមថ្លៃព្រះទ័យខ្វល់　　អម្ពល់នឹករៀមដែរដឹងអឺយ ។
ពីកាលដែលចេញពីរាជឋាន　　ទៅបានរួមរាក់ស្នេគ្រក្បៀកកើយ
រួមរសម្ងួលមិត្តស្នេហ៍ស្និទ្ធហើយ　មិនស្បើយវិយោគសោកសែនទ្វី ។

ឥឡូវរៀមរាក់នឹងទៅឆ្ងាយ ថ្លើមម៉ាយរៀមសូមផ្តាំនារី
កុំយាងចេញចោលឆ្ងាយពីទី ក្រែងគេមើលងាយណាធីតា ។
ដ្បិតមនុស្សឥឡូវវាទុច្ចរិត ប្រែចិត្តដូចអ្នកក្រៅសាស្នា
រង់ចាំទំរាំតែជេដ្ឋា មកដល់ថ្ងៃណាសិមយាងទៅ ។
អាសូរចិត្តរៀមដែលក្រៀមក្រំ ប្រឹងទៅទាំងខំទាំងផ្សាក្តៅ
មានតែវិយោគសោកសែនសៅ មួម៉ៅមិនមានក្សាន្តសោះឡើយ ។
១ថ្មើរណោះម្លេះសំផ្ទុំសុខស្កល់ ឬមួយទ្រង់ខ្វល់ក្នុងទៃយា
រឭកមករៀមដែលឃ្លាតឃ្លា ជាច្រើនទិវាក្រយង់យល់ ។
ឬមួយក្សាន្តសោះអស់នឹងនា កម្មធំក្នុងគ្រានេះអកុសល
រិះគិតរីតកើតចិត្តឆ្អិតឆ្អល់ រវល់ញឹកញាប់រាប់មិនបាន ។
គិតសព្វថប់ណែនហើយថែមព្រួយ ស្មើរនឹងរលួយថ្លើមប្រមាត់
មើលទៅជាជាំធំព្រោះគ្មាន ទីតាំងតែប្រាសថ្លើមថ្លៃ ។
ថ្លៃបងចូរកែវទ្រង់អាណិត មកចិត្តដែលពិតគិតអាល័យ
កុំឱ្យអសារសោះទីទៃ រិះរើសសេចក្តីឱ្យសព្វសាយ ។
ចិត្តអើយគង់ចាំពាក្យសន្មត ក្រែងអត់អំពើទេចិត្តាយ
ព្រះទ័យកំពប់រុសរាក់រាយ ដោយឆ្ងាយបង់បាត់ខ្ចាត់វាចា ។

សព្វថ្ងៃយកព្រះជាទីពឹង ពំនឹងដោយទិព្វចក្ខុ
ឱ្យប្រាប់រឿងថ្លៃថ្លើមជីវ៉ា គ្រាន់ស្ងប់ទុក្ខាស្ងប់ស្ងៀមនៅ ។
មួយគិតប្រណីមកឆោមយង់ ឱ្យគង់កេរ្តិ៍យសតរៀងទៅ
ចិត្តចង់ឱ្យល្អពង្សវង្សផៅ កុំឱ្យអ្នកក្រៅគេនិន្ទា ។
មួយដូចខ្លួនបងតូចទាបស័ក្តិ វរល័ក្ខណ៍ខ្ពង់ខ្ពស់ដូចមេឃា
ពុំគួរបើហ៊ាននឹងពុះពា ប៉ុន្តែចិន្តាស្នេហាសល់ ។
មួយពុំចង់ឱ្យមនុស្សទាំងឡាយ គេដឹងខ្ចរខ្ចាយកើតកង្វល់
អប្រិយ៍ព្រោះចិត្តអកុសល ថ្លៃវិះដល់រក្សាអង្គ ។
មួយកុំរវល់នឹងចិត្តបង ថ្វាយស័ក្តិដែលប៉ងគិតបំរុង
ក្រែងតែព្រះទ័យថ្លៃឆោមយង់ ពុំគង់ដូចព្រះបន្ទូលឡើយ ។
ស្ងួនអើយចិត្តរៀមដូចកល់ភ្នំ សុមេធាធំនៅឯព្ហ
សង្កត់ទ្វីបប្អូនធ្ងនសព្វថ្ងៃ អាស្រ័យកំរើកចេញមិនបាន ។
កុំព្រួយព្រះទ័យឡើយធីតា បើវះឱរារៀមក៏ហ៊ាន
វះថ្វាយទ្រង់ទតជាក់ស្មោះស្មាន កល្យាណជឿចុះកុំសង្ស័យ ។
ប្រសិនបើវាស្នាយើងមាន គង់ជួយឱ្យបានដូចបច្ច័យ
ដ្បិតយើងបន់ព្រះតែសព្វថ្ងៃ អាស្រ័យឱ្យបានដូចប្រាថ្នា ។

ដឹងហើយជាក្រជាចង្អៀត ហើយទ្រង់ខំឆ្លៀតដល់ជេដ្ឋា
ជឿហើយជាព្រះទ័យមេត្តា ជេដ្ឋាក៏ឥតមានសង្ស័យ ។
ទោះមនុស្សនាំញុះញង់ដូចម្ដេច រៀមក៏ពុំភ្លេចក្ដីអាល័យ
តាមបុណ្យតាមព្រេងតាមនិស្ស័យ សេចក្ដីអាល័យកាត់មិនបាន ។
ថ្ងៃមុនមានចុតម៉ាយមួយច្បាប់ ថ្លែងប្រាប់ថាអផ្សុកក្នុងកាយ
កើតគ្រុនស្រៀវស្រាញមិនសប្បាយ ប្រែក្លាយឈឺដល់ព្រះកេសា ។
នោះរៀមបានតបសារមកវិញ ថាដ្បិតរៀមម្នេញក្នុងចិន្ដា
បើជាអផ្សុកដូចម្ដេចម្ដា ឱ្យសារតបទៅជាប្រញាប់ ។
ចុតម៉ាយមកនោះឥតអំពើ បំរើក៏ពុំឃើញទៅប្រាប់
ក្មេងដើរចេញចូលដូចគេសាប់ គ្មានប្រាប់ឱ្យធូរក្នុងឱរា ។
ជាទុក្ខទន្ទឹងដំណើងស្ងួន ប្រឈួនព្រះរោគតើយ៉ាងណា
បន្ដិចលេចក្មេងទៅប្រាប់ថា ធីតាអផ្សុកបីថ្ងៃហើយ ។
ឱថ្លើមតែមួយជាត្រួយចិត្ត រៀមគិតគ្មានភ្លេចដល់តិចឡើយ
រីងរីតទោមនស្សពុំមានស្បើយ កែវអើយបើម្លេះសមរៀមក្ស័យ ។
ទោះដើរទោះដេកអង្គុយលេង សព្វល្បែងតែងនឹករឭកថ្លៃ
សមបាត់ដំណើងរីងសង្ស័យ ទាំងយប់ទាំងថ្ងៃដេកមិនលក់ ។

បីបួនប្រាំថ្ងៃនេះមកហើយ ព្រលឹងកែវអើយរៀមគ្មានសុខ
គ្មានក្សាន្តដោយខានបានឃើញមុខ ជាទុក្ខរន្ធត់ស្លុតស្មារតី ។
នឹកពីយើងកើតរួមពសុធា ក្រុងកម្ពុជារាជបុរី
ម្ដេចឡើយមកឆ្ងាយអស់សេចក្ដី គួរអ្វីមិនដឹងដំណឹងអ្នក ។
ព្រះរោគតើប្រែយ៉ាងដូចម្ដេច ជាតិចឬច្រើនថ្លែងឱ្យជាក់
ឬមួយគ្រាន់បើហើយវរល័ក្ខណ៍ រៀមចង់ឱ្យជាក់ថ្ងៃនេះឯង ។
ដ្បិតចិត្តគិតថប់បារម្ភណាស់ ចង់ច្បាស់ព្រះរោគនោះចំបែង
ក្សត្រីមេត្តាចូរថ្លាថ្លែង សូរិឆាយសាយសែងឱ្យដល់ទៅ។
ស្រងូតស្រងល់ខ្វល់ពន់ពេក ដូចមេឃនឹងទឹកអ័ព្ទទិសា
ក្ដួលក្ដុកចុកណែនក្នុងឱរា អនិច្ចាចៅកម្មនាំបំភ្លាត់ ។
កាលនៅក្នុងអសោកឱទ្យាន ដ្បិតមានអ្នកធំគេពង្រាត់
បង្រាសឱ្យប្រាសឱ្យព្រាកព្រាត់ បំភ្លាត់ដោយនៅអំណាចគេ ។
យើងក៏រងកម្មទ្រាំវេទនា រាល់ម៉ោងពេលាឥតទំនេរ
ពេលស៊ីៗ សុទ្ធតែទុក្ខទេ ធ្វេសធ្វេសាយសព្វសរពើរផង ។
ឃ្លាតគ្នាខានយល់មកពីរខែ ឃើញតែចុតម៉ាយឡាយម្ដងៗ
ម្លោះហើយអម្ពល់សល់សែនម៉ង ចិត្តចងចង់ចាប់តែទោសា ។

ក្តៅក្តួលរំជួលដូចភ្លើងឆេះ រលេះរបោចខ្លោចឱរា
ទ្រូងត្រួតដំរួតតែទុក្ខា អនិច្ចាមុខគួរអាសូរកាយ ។
ឥឡូវគិតស្មានថាបានជិត ព្រោះដឹតបែកបាត់មកឋានអាយ
ចៅកម្មដែលចាំក៏អន្តរាយ ខ្ចាត់ខ្ចាយដោយគុណបុណ្យបារមី ។
គិតស្មានបានជួបជួនស្នេហ៍ស្និទ្ធិ រួមចិត្តរួមខ្លួនស្ងួនប៉ែតី
មិនមានអន់អាក់ថ្នាក់នឹងអ្វី តែក្តីឥតទីនឹងអាស្រ័យ ។
នឹងសុំសំណាក់ដោយផ្ទះគេ ចាស់ជួរខឹងខេរខូចពេកក្រៃ
បណ្តេញទន្ទេញស្តីរុំារ៉ៃ អាស្រ័យជ្រកកោនផងពុំបាន ។
ឯរៀមតាំងពីត្រឡប់ទៅ សុបសៅល្វែល្វិតឥតវិញ្ញាណ
ស្រមៃឃើញថ្ងៃនៃបជិតប្រាណ ទើបបានប្រុងប្រែបែរប្រវា ។
លើកហត្ថបីបមហើយថ្នមថ្នាក់ អង្អែលឱបដាក់លើឱរា
ឱបទៅពានខ្មៃយនៃបកាយា នេត្រាហូរល្វែងស្រក់សស្រាក់ ។
សមសូរផ្គរលាន់ឮរងំ រៀមកើតទុក្ខធំក្រាំអួលអាក់
ចំបែងកណ្តែងម្នេញតែម្នាក់ ឆោមភ័ក្ត្រនឹករៀមដែរឬអ្វី ។
ឯរៀមរីងរីតចិត្តថែមត្រួត ដំរួតអាល័យដល់ពីរបី
សែនគុណលានគុណទៀតណាថ្លៃ ម្តេចពុំប្រណីទ្រូងរៀមផង ។

បំណាច់កើតក្នុងខត្តិយវង្ស ម្ដេចឡើយមិនទ្រង់ជ្រាបទំនង
ពីទុក្ខពីមានក្ដីសៅហ្មង ពីចិត្តទ្រាំរងកម្មរាល់ថ្ងៃ ។
ឱគូជីវិតមិត្តមួលមួយ ជាត្រួយបណ្ដាច់ដួងហប្ញទ័យ
ពុំគិតស្ដាយជន្មជីវិតក្ស័យ ឱថ្ងៃថ្លើមរៀមផ្ញើជន្មបាន ។
សព្វថ្ងៃយកព្រះជាទីពឹង ពំនឹងផ្សងតាមបុណ្យបុរាណ
បំណាច់ព្រះទ័យដែលរាប់អាន ឱ្យបានដូចចិត្តគិតប្រាថ្នា ។
កនិដ្ឋាចិន្ដាឈ្លេងដូចម្ដេច ឬភ្លេចបន្ទូលដែលសញ្ញា
ជាមួយនឹងព្រះជាជេដ្ឋា សច្ចាគ្រប់សព្វឥតចន្លោះ ។
ស្ងួនអើយបើវាស្នាយើងមាន គង់តែនឹងបានជាស្នានស្មោះ
មិនមានខ្វែប្រែទៅណាសោះ ដូចកលរបស់ក្នុងលំនៅ ។
ខំរៀបរក្សាគិតថែទាំ ប្រុងចាំកាលណានឹងបាត់ទៅ
ដូចកលកនិដ្ឋាថ្លាឆោមឆ្លៅ ចាំព្រះទ័យនៅមិនភ្លេចឡើយ ។
បើបានមកដល់សូមមេត្តា តតបសារ៉ាកុំកន្ដើយ
ឱ្យទានរៀមវ័ក្សអ្នកបានស្បើយ ថ្លើមអើយអាសូរចិត្តរៀមផង ។
បំណាច់បានមកប្រសព្វគ្នា កុំឱ្យកំព្រាពេកឡើយហោង
សូមស៊ូជីវិតជាមួយផង ថ្លៃបងសូមមាសមានមេត្តា ។

ឱ្យទានដំណឹងដល់រៀមរ័ក្ស　　ដែលជាប់ជំពាក់ដោយតណ្ហា
ក្តៅក្តួលរំជួលក្នុងឱរា　　នេត្រាហូរល្វែងស្មើរនឹងក្ស័យ ។
ក្សត្រីមិនទតមករៀមសោះ　　ចរចុះអស្សប្ញទ្ធីបើកឃ្លាឃ្លៃ
នេត្រារៀមរ័ក្សរវែងរំពៃ　　ក្សត្រីលុះផុតវេលានោះ ។
វិលឡើងមកឯលំនៅវិញ　　ទ្រូងម្នេញតែម្នាក់ឯងម៉ងម្ល៉ោះ
មិនគួរនឹងកាត់ព្រះទ័យសោះ　　គេចដោះចោលរៀមគ្មានសង្ស័យ ។
មានបំរើពីលោកធរមា　　ហៅរៀមជានេះណាវេលាថ្ងៃ
ពុធពីរដណ្តប់ខែជេស្ឋនៃ　　ហើយលោកប្រាស្រ័យប្រើរាជការ ។
ថ្ងៃមុនមានចុតហ្មាយ ១ ច្បាប់　　ថ្លែងប្រាប់ទៅថាវរក្សត្រី
ខានពុំបានទៅហែឡើយនៃ　　សេចក្តីបានសួរទៅរៀមថា ។
ទៅហែឬពុំបានទៅឡើយ　　ចុតហ្មាយរៀមឆ្លើយតបសព្វសា
បើទ្រង់ខានទៅដូច្នោះណា　　ជេដ្ឋាក៏ពុំបានទៅដែរ ។
លុះដល់ស្តេចយាងដំណើរទៅ　　ក្សត្រីឆោមឆ្មៅហែទៅហើយ
ខុសនឹងសញ្ញាដែលឆ្លះឆ្លើយ　　ថ្លើមអើយរៀមថប់គ្រប់ប្រការ ។
រៀមឃើញកនិដ្ឋាយាត្រាឆ្ពោះ　　ចរចុះអស្សប្ញទ្ធីវេលាណា
..................................　　............................... ។

ថាឱ្យទៅចំរើនពន្លស្រូវ ឱ្យទៅក្នុងថ្ងៃនោះឯងណា
ឯរៀមពុំបានប្រកែកថា ដោយសារខ្លួនតូចទាបយសស័ក្តិ ។
ចេញដើរទៅចំរើនពន្លស្រូវ តាមផ្លូវទៅចិត្តគិតអួលអាក់
នឹកដល់កនិដ្ឋាថ្លាវរល័ក្ខណ៍ កើតអាក់តើពីព្រោះរឿងអ្វី ។
ទើបទៅពុំមានបន្ទូលប្រាប់ ឱ្យដឹងសាស័ព្ទសព្វសេចក្តី
ស្រាប់តែស្តេចយាងចុះអស្សវី សំឡឹងព្រះទ័យហាក់ដូចស្បើយ ។
ឬមួយមានមនុស្សទូលញុះញង់ ឱ្យទ្រង់អន់អាក់ទេដឹងអើយ
ទើបទៅពុំមានបន្ទូលឆ្លើយ ព្រងើយពុំឱ្យដឹងស័ព្ទសា ។
ខំធ្វើរាជការតែទាំងទុក្ខ ក្តីសុខពុំមានសោះឡើយណា
ចំរើនបានពីរបីទិវា ឮថាស្តេចយាងមកវាំងវិញ ។
បញ្ឈប់ពន្លរាជការនោះទុកស្លេះ គេចវេះមកពីគិតអម្ពេញ
ឱ្យចួបនឹងក្សត្រីសំឡាញ់ នឹងកាញ់ទូលសួរឱ្យដឹងការ ។
តឡូវថាមានគេទូលថ្លែង ថារៀមនេះឯងចរយាត្រា
សំដៅទៅនៅនឹងភរិយា នរណាតើគេទូលក្សត្រី ។
រៀមចង់ឱ្យជាក់ដំណើរនោះ ឱ្យដឹងចំពោះសព្វសេចក្តី
ឬមួយកនិដ្ឋាក្លែងបំភ័យ ឱ្យរៀមនេះនៃព្រួយរិះគិត ។

សព្វថ្ងៃស្លាប់រស់ពុំគិតខ្លួន ល្វែងតែបានជួនជួបឆោមស្និទ្ធ
ឥឡូវប្រែថារៀមទ្រុស្តមិត្ត កែគិតក្បត់ថ្លៃកនិដ្ឋា ។
រៀមនេះត្រង់ណាស់កុំសង្ស័យ ទ្រង់ថ្មៃនោះខុសនឹងទេវតា
ដោយគូវ៉ានៅជាសុខសព្វព្រឹក្សា ភ្ញាក់កាលណាឃើញនៅមុខទុក្ខបានស្បើយ ។
តែខ្លួនបងកំព្រារងាឱបតែខ្នើយ ឱ្យកម្មអើយធ្វើកម្មអ្វីក៏ដល់ម្ល៉េះ ។
សារមេត្រីតែងដោយក្ដីភិសរង់ ផ្ញើមកត្រង់ចង់ឱ្យដឹងពីចិន្ដា
ពីចិត្តបងគិតមួយត្រួយជីវ៉ា ពុំចង់ឃ្លាឱ្យជាឃ្លាតមួយរាត្រី ។
តែរៀមកាត់ដោយជាតិសត្វកើតក្នុងកម្ម វែងតែចាំទ្រាំតែទុក្ខជាប្រក្រតី
នឹងចៀសចាក់ពីសង្សារនាលោកិយ ទោះប្រុសស្រីវែងដូចគ្នារាល់រូបា ។
ម៉ោងប្រាំបួនចូនគេទួងយាមប្រែប្រាណ ចិត្តគិតស្មានដូចបានថ្នើមថ្លៃ
ដោយជាសុខលក់ស៊ុនហួសដល់ថ្ងៃ ចិត្តគិតថ្មៃដោយខ្វល់ដល់ក្ដីវេទនា ។
បើជឿជាក់ហើយពុំសង្កា សូមមានអក្ខាតបទៅវិញ ។
នៅណាកែវណារៀមលាទៅ ធីតាគង់នៅរក្សាអង្គ
ខំប្រឹងព្រះទ័យថ្លៃផ្ចិតផ្ចង់ ដំរង់ទំរាំរៀមមកវិញ ។
រៀមទៅតែប្រាំពីរទេវ៉ា មិនហ៊ានយូរយារទេកុំម្ញេញ
អផ្សុកព្រះទ័យដូចម្ដេចមិញ កុំចេញក្រសាលដោយបឹងបួរ ។

ដ្បិតមនុស្សឥឡូវច្រើនអាក្រក់ ភរភូតកុហកចិត្តជងជូរ
វានាំបំបែកមិនគិតគួរ ដោយសារចិត្តជួរចោរសាម៉ាន្យ ។
វាគិតនាំយកឈ្មោះទៅលក់ សព្វភូមិសព្វស្រុកឱ្យតែបាន
កាសប្រាក់ចាយលេងជាកំសាន្ត កល្យាណអាសូរចិត្តជេដ្ឋា ។
រៀមទៅម្ដងនេះពេញមានទុក្ខ ចិត្តចុករំខាន់ណាស់កល្យាណ៍
ខ្លួនទៅចិត្តនៅនែបស្នេហា មិនបែកទៅណាទេក្សត្រី ។
ខ្លួនបងមិនជាមនុស្សសាមាន្យ រំខានចិត្តគិតដល់ពីរបី
មិនផ្លាសដូចសាសន៍អន្យតិរ្ថិយ ឃើញស្រីហើយចេះតែចូលជិត ។
បើសូ្បថរៀមរ័កក៏ហ៊ានសូ្បថ ប្រាកដដូច្នេះឯងពិត១
មួយរយស្រីទៀតរៀមមិនស្និត ផ្ញើជន្មផ្ញើចិត្តលើធីតា ។
ប្រសិនលេបបានដូចចំណី នឹងលេបក្សត្រីសោះសង្កា
ភ្នកនឹកសិមខ្វាក់មកស្នេហា រួមរួចកាលណាលេបឱ្យបាត់ ។
កនិដ្ឋាពំងាថ្លើមកែវអើយ ថ្ងៃនេះឯងហើយអនុជអ្នក
បែកបែរខានស្នេហ៏ខានរួមរ័ក ខានស្ម័គ្រខានស្មោះចំពោះកាយ ។
ឱចិត្តយើងអើយសែនចម្បែង នៅជិតកន្លែងហាក់ដូចឆ្ងាយ
ទាល់ទៀតចង្អៀតទៅសព្វសាយ គ្មានហៅទូលាយរឿងត្រង់ណា ។

បើខានស្នេហ៍លែងតែយល់ភ័ក្ត្រ បើខានស្នេហ៍គ្រលែងតែចរចា
បើខានតទល់នឹងឱស្ឋា លែងតែអក្ខរាទៅមកបាន ។
គ្រាន់នឹងកែកើយរំហើយចិត្ត កែក្ដីដែលស្និទ្ធិឱ្យគ្រាន់ក្សាន្ត
ឥឡូវមាររាំងខាំងបង្ខាន សមបានតែក្ដីក្ដៅវេទនា ។
ម្ល៉េះសមរៀមទ្រាំតែទឹកភ្នែក កនិដ្ឋាពំងាថ្លើមកែវអើយ
ថ្ងៃនេះឯងហើយអនុជអ្នក បែកបែរខានស្នេហ៍ខានរួមរ័ក
ខានស្នេហ៍គ្រខានស្នោះចំពោះកាយ ។

ឱចិត្តយើងអើយសែនចម្បែង នៅជិតកន្លែងហាក់ដូចឆ្ងាយ
ទាល់ទៀតចង្អៀតទៅសព្វសាយ គ្មានហៅទូលាយរឿងត្រង់ណា ។
បើខានស្នេហ៍លែងតែយល់ភ័ក្ត្រ បើខានស្នេហ៍គ្រលែងតែចរចា
បើខានតទល់នឹងឱស្ឋា លែងតែអក្ខរាទៅមកបាន ។
គ្រាន់នឹងកែកើយរំហើយចិត្ត កែក្ដីដែលស្និទ្ធឱ្យគ្រាន់ក្សាន្ត
ឥឡូវមាររាំងខាំងបង្ខាន សមបានតែក្ដីក្ដៅវេទនា ។
ម្ល៉េះសមរៀមទ្រាំតែទឹកភ្នែក សង្វេគរាល់ម៉ោងរាល់ពេលា
ដ្បិតធ្លាប់បានស្និទ្ធជិតនឹងគ្នា គ្រានេះប្រែជាបែកដូច្នេះ ។
ឥឡូវសូមសុំព្រះចិន្ដា សូមទ្រង់មេត្តាថ្លាត្រេកត្រ៊ិះ

ព្រះទ័យតែមួយកុំវៀចវេះ សមរៀមនឹងប្រេះទ្រូងមិនខាន។
ខំទ្រាំទំរាំតែវាស្នា ជូនជួយកាលណាគង់តែបាន
ដូចក្ដីប្រាថ្នាចិន្ដាក្សាន្ដ កល្យាណកុំព្រួយព្រះទ័យា ។
នៅណាកែណារក្សាអង្គ ខំផ្ចង់ព្រះទ័យឱ្យគង់កេរ្ដិ៍
កុំស្រើបកុំស្រោលតាមពាក្យគេ កុំធ្វេសកុំធ្វើប្រហែលកាយ ។
ដ្បិតទ្រង់គង់ក្នុងធុរៈធំ វាស្ត្រទាសកុះកុំពឹងឆោមឆាយ
កុំឱ្យសៅហ្មងដល់អង្គកាយ ដ្បិតរៀមទៅឆ្ងាយពុំបានថ្នម។

## សេនាបតីក្រសួងព្រះរាជវាំងក្លែងធ្វើជា
## ប្រើឲ្យចេញទៅដើរកាត់ពន្ធស្រូវ

ជេដ្ឋាតាំងតែកើតកលិយុគ ពេញទុក្ខពេញហៅសែនវេទនា
មិនមានអ្នកណាមួយជាគ្នា វេទនារោគរុំជុំអង្គកាយ ។
និត្យនៅក្នុងព្រៃពោធិព្រឹក្ស ម្រឹគនូវសព្វសត្វផងទាំងឡាយ
សប្បាយតាមដោយដងព្រឹក្សា ។
មិនព្រាត់មិនប្រាសនិរាសចេញ មិនម្នេញនឹងឃ្លាតសាច់សង្សារ
តែអង្គឯកកាយឆ្ងាយកនិដ្ឋា ខ្លោចផ្សាស្មើរស្មូនឲ្យជន្មជីវិត ។

នឹកថាឱអង្គអនុជនាង　　កុំឱ្យសៅហ្មងដល់អង្គកាយ
ដ្បិតរៀមទៅឆ្ងាយពុំបានថ្នម ។

# សេនាបតីក្រសួងព្រះរាជវាំងក្លែងធ្វើជា
# ប្រើឲ្យចេញទៅដើរកត់ពន្ធស្រូវ

ជេដ្ឋាតាំងតែកើតកលិយុគ　　ពេញទុក្ខពេញហៅសែនវេទនា
មិនមានអ្នកណាមួយជាគ្នា　　វេទនារោគរុំជុំអង្គកាយ ។
និត្យនៅក្នុងព្រៃពោធិព្រឹក្ស　　ម្រឹគនូវសព្វសត្វផងទាំងឡាយ
ហើរដើរច្រវាត់ខ្វាត់ជិតឆ្ងាយ　　សប្បាយតាមដោយដងព្រឹក្សា ។
មិនព្រាត់មិនប្រាសនិរាសចេញ　　មិនម្តេញនឹងឃ្លាតសាច់សង្សារ
តែអង្គឯកកាយឆ្ងាយកនិដ្ឋា　　ខ្លោចផ្សាស្មើរស្មូន្យជន្មជីវិត ។
នឹកថាឱអង្គអនុជនាង　　លោឃ្លាតមិនដូចចិន្តាគិត
ពីកាលរួមឋានបានមូលមិត្រ　　ស្មានពិតថាជន្មផងគ្នា ។
ឯឡូវមកកើតហេតុដូច្នេះ　　បើម្ល៉េះកាលណារួចជន្មា
បានឃើញចុតហ្មាយឡាយអនុជា　　លេខាមានសព្វគ្រប់សេចក្តី ។
រៀមគ្រាន់ស្រាន្តស្រាលអស់ទុក្ខសោក　　វិរោគក៏ស្បើយតាំងពីថ្ងៃ

នោះឯងមកពិតឥតសង្ស័យ តែក្តីអាល័យពុំមានស្បើយ ។
កនិដ្ឋាមេត្តារៀមផងចុះ រៀមស្មោះណាស់ណាថ្លើមកែវអើយ
មិនបែរកែគិតចិត្តចេញឡើយ ម៉្លេះហើយសូមស្ម័ជន្មផងគ្នា ។
យើងអើយហៅពេញសែនកំសត់ ម៉្លេះហើយបើក្បត់ចិត្តនឹងគ្នា
ពុំគង់ដូចពាក្យដែលសន្ទនា ទេវាបំផ្លាញល្ហមសុខចិត្ត ។
ស្ងួនអើយពីរៀមវិលទៅវិញ ទ្រូងម្ទេញប្រាសប្រាណរំខានគិត
នឹកដល់និមិលថ្លៃថ្លើមស្និទ្ធ ក្តួលចិត្តរឭកនឹកពុំស្បើយ ។
កនិដ្ឋាតើនឹករៀមដែររឺ ឬរាជក្សត្រីពុំនឹកឡើយ
បើនឹកក៏នឹកតែយ៉ាងឆើយ ឆាប់ស្បើយមិនកាន់កំណាន់នៅ ។
សំកាលជាតិមុនយើងពង្រាត់ បម្រាសគូសត្វបំបាត់ទៅ
រួចនាំមកឱ្យរួមលំនៅ រួមរួចហើយទៅបំបែកទៀត ។
ឱ្យតែរហែនឹងរហល់ រវល់ឱ្យមានក្តីចង្អៀត
បានជាយើងបានចួបហើយឃ្លាត ហើយបានចួបទៀតដូច្នេះឯង ។
ឯចួបក៏ចួបទាំងភ័យភិត បារម្ភក្នុងចិត្តគិតចម្បែង
មិនបានស្រួលចិត្តគិតឯកឯង គិតក្រែងសត្រូវផ្លូវគ្រប់ច្រក ។
ហេតុនេះមានក្តីវេទនាណាស់ ដូចគេកាប់ច្រាសឈាមខន់កក

មួយដូចយកឈើទៅប្រហក ហើយដកយកដួងចិត្តនេះទៅ ។
សង្វេគចិត្តណាស់សែនវេទនា មិនមានអ្នកណាឃើញទុក្ខសោះ
ប្រឹងថាតែខ្លួននេះមិនស្មោះ គេចដោះទៅជ្រករកដើមដាន ។
ធ្វើម្តេចនឹងបានឋានជាមួយ សោះព្រួយឱ្យមានក្តីរំខាន
បើឃើញចិត្តជាក់ជាស្ម័គ្រស្មាន នោះហ៊ានថ្វាយទោសតាមអាជ្ញា ។
សព្វថ្ងៃរំពៃដូចកលក្អែក មិនបែកបាក់បែរប្រែទៅណា
ខ្លួនទៅចិត្តនៅនែបស្នេហា នឹងកែវកនិដ្ឋាមិនដាច់ឡើយ ។
រាត្រីស្រងាត់សត្វដេកស្ងៀម ទ្រូងរៀមមិនចេះហៅមានស្បើយ
តែព្នាលិកកាលណាហើយ ថ្លៃអើយស្មើរធ្លាក់ថ្លើមធ្លុះធ្លាយ ។
ដណ្តើមទាំងក្រហើយមានទ័ល ដុះជាសំគាល់ទាំងសម្មាយ
បណ្តាលឱ្យចិត្តគិតរាយមាយ ដូចវាយវាវរណ្តៅពន្ធព្រឹក្សា ។
ឯវាយអាស្រ័យតែលើព្រឹក្ស ទើបលូតលាស់ស្លឹកលំពង់ផ្កា
បើគ្មានដើមឈើនឹងពឹងពា កាលណានឹងដុះលាស់ឡើងបាន ។
ដូចកលទ្រូងរៀមជាទុក្ខធ្ងន់ ផ្ទើជន្មផ្ទើចិត្តលើកល្យាណ
បើមិនមេត្តានឹងទាត់ច្រាន នោះរៀមក៏មានតែវេទនា ។
ដូចកលកូនសត្វព្រាត់សំបុក ជាទុក្ខមិនដែលសល់ពេលា

ញផ្គរហើយត្រូវភ្លៀងរងា កំព្រាព្រួយប្រាណឥតគេរាប់ ។
ដូចសេកហើរត្រេករកសាលិកា ចួបចាប់ស្នេហាជាគូគាប់
បើសាលិកាពុំគំនាប់ រាប់រកធ្វើម្ដេចសេកនឹងហ៊ាន ។
ដូចព្រះមហោសថបុត្រសេដ្ឋី ចេញពីបុរីក្រុងរាជដ្ឋាន
វិវេកសង្វេគឯកអង្គប្រាណ ព្រោះតែចង់បានរាជពនិតា ។
ទៅបានលើភ័ព្វគាប់ចួបជួន ប្រទះលើខ្លួននាងអមរា
យល់ហើយសាសងលងប្រាជ្ញា លុះត្រាតែបានជាគូគ្រង ។
មួយសោតដូចព្រះដាវរឿងរាជ ឯងអាចឥតមានក្ដីខុសឆ្គង
ចាស់ភ័ក្ត្រកាឡីស្រីដកទង វាធ្វើឱ្យហ្មងទាល់ព្រាត់ប្រាស ។
នេះអកុសលចំពោះពិត ពុំជិតជាក់ជាកម្មកាចក្រាស់
ថ្លៃអើយផ្ចង់ចិត្តឱ្យស្រឡះ សំពះនឹកត្រឹមតែព្រះគុណ ។
អនិច្ចាសង្សារក្ដីស្រឡាញ់ ពុំគួរប្រាសចេញពីឱរា
រៀមតាំងចិត្តពិតនឹងកនិដ្ឋា ពាក្យដែលប្ដេជ្ញាគង់ចាំពិត ។

១រសៀលជ្រៀលជ្រេព្រះសុរិយា ភេត្រាបើកដល់ហៅដីច្រាល
រៀមនឹករឭកឆោមកល្យាណី ប្រាសប្រាណកាយកែលបែរកើយភ្នំ ។

លើកហត្ថដាក់គង់លើកសិលា ព្រួយក្នុងទ័យាមិនមានក្សាន្ត
សន្ទែសន្ទឹករន្ធត់ប្រាណ ពុំបានយល់ភ័ក្ត្រវរធីតា ។
ឱដួងចំរើនស្និទ្ធចិត្តរៀមរ័ក្ស មិនគួរនឹងអាក់នៃចិន្តា
ពេញចិត្តស្នេហ៍ស្និទ្ធដូចនេត្រា ស្នេហាសព្វថ្ងៃស្មើជីវិត ។
ភ្លេចខ្លាចអំណាចព្រះភូវនៃយ ព្រោះតែអាល័យកនិដ្ឋា
ជីវិតមិនស្តាយទាំងកាយា នឹកថាស៊ូស្លាប់ទៅទើបជា ។
សែនរំជួលក្តួលក្តៅឱ្យស្មៅហ្មង ដ្បិតបងប្រាសចាកចោលស្ងួនភ្ងា
សង្រេងសង្រៃគ្រប់ពេលា កាលណានឹងបានចួបចួនកាយ ។
តែងទូលអង្វេរទេពទេវា ដែលឋិតនៅនាទីឋានអាយ
ខ្ញុំសូមផ្ញើប្អូននៅសប្បាយ ទុក្ខភ័យអន្តរាយកុំបីមាន ។
ទាំងខ្លួនជីវិតឈ្មោះក្តីណា សូមទ្រង់មេត្តាមើលឱ្យទាន
ក្រែងមានសត្រូវទៅបៀតបៀន ប្រោសប្រាណឱ្យទានមានប្រណី ។
ដ្បិតខ្លួនខ្ញុំសោតនៅទីឆ្ងាយ ពុំដឹងមកអាយជាក្រក្រី
ក្រែងគ្រោះបង្អើតមានរោគអ្វី តេជះបារមីទ្រង់រក្សា ។
ឱប្អូនព្រលឹងមានបណ្តូល បណ្តាច់មូលមួយស្មើជីវ៉ា
តែនឹកដល់ទីក្តីស្នេហា ឈឺផ្សាក្តៅក្តួលសព្វសាយ ។

បើជាពិសសរសោតពុំទាន់ ជាក់ស្បានដូចគ្រានេះប្អូនណាយ
ទុក្ខទ្រាំជាំក្រំពុំរសាយ កម្មកាយបង្កើតឱ្យវេទនា ។
អផ្សុកព្រោះនឹករឭកដល់ ធ្វើម្តេចនឹងបានយល់ស្ងួនភ្ងា
បើស្តេចត្រឡប់ចូលភារា បានឃើញស្ងួនភ្ងាដូចចិត្តគិត ។
ទ្រូងខ្ញុំសព្វថ្ងៃណែនសែនផ្សា សូមអស់ទេវតាជួយអាណិត
ជួយឱ្យស្តេចវិលចូលឋានឋិត ខ្ញុំបានចួបស្និទ្ធដូចប្រាថ្នា ។
អនិច្ចាចិត្តអើយមិនក្លែងក្លាយ អង្គកាយកើតមកជាមនុស្សា
មានចិត្តស្លូតត្រង់ណាស់ទេវតា វាចាត្រង់ណាក៏មិនឆ្លើយ ។
មានមែនគូដែលបានគ្រប់គ្រង គេកើតសៅហ្មងមកយូរហើយ
កាលទ្រង់យកទោសនោះថ្លើមអើយ គេឆើយមិនដែលទៅមកសោះ ។
ឯរៀមកាត់ចិត្តឥតសង្ស័យ ពីថ្ងៃដែលទ្រង់យកទោសខុស
មិនដែលមេត្រីស្តីចេញឈ្មោះ ចំពោះពិតត្រង់ដូចវាចា ។
កាត់ចិត្តកាត់ស្និទ្ធកាត់អាល័យ កាត់ពីពិសម័យក្តីស្នេហា
ទើបតែដល់គ្រានេះឯងណា មកថ្លែងវាចាសុំមានប្តី ។
ឯរៀមក៏គន់គិតមេត្តា ចិន្តាគ្មានចិត្តគិតមេត្រី
ព្រមបើកឱ្យគេមានស្វាមី សេចក្តីសំរេចស្រេចហើយណា ។

ហើយគេក៏ត្រឡប់វិលវិញ　　គេពុំមានម្ទេញទេធីតា
គេវិលក្នុងថ្ងៃនោះឯងណា　　មិនជឿវាចាស៊ើបសួរចុះ ។
ឱ្យកែវកនិដ្ឋាសង្សារសត្វ　　ដូចកល់ប្រមាត់បាត់ក្នុងថ្លើម
ទងគួបរួបជាប់ជាមួយដើម　　ដង្ហើមចេញចូលតែផ្លូវមួយ ។
មិនមានបែកចិត្តគិតចោលចេញ　　ឱ្យម្ទេញឱ្យគិតប្រែចិត្តព្រួយ
គិតតែកែវឆ្នើមថ្លើមមូលមួយ　　សព្វថ្ងៃរលួយរលីងចិត្ត ។
ចូលទៅសំណាក់ព្រះកម្មដ្ឋាន　　ប្រាថ្នាចង់បានក្ដីដែលស្និទ្ធ
ឱ្យគុណជូនជន្មជួយជិវិត　　ឱ្យជិតមិត្រមូលស្រួលដូចដើម ។
កុំឱ្យមានកម្មអកុសល　　មកផ្ដល់ដូចជាន់មុនណាឆ្នើម
ប្រមាត់មិនដែលខ្ចាត់ពីថ្លើម　　សន្ទើមមិនដែលខានចុះឡើយ ។
ព្រោះតែអំណាចខ្យល់បក់ខ្លាំង　　ខណ្ឌខាំងបោកបាតផាត់ផាសផើយ
លុះត្រាតែខ្យល់កំឡាំងស្បើយ　　ថ្លើមអើយសន្ទើមចុះជោកវិញ ។
រឿងនេះសូមថ្លៃមាសមេត្តា　　ពាក្យវដ្ដសង្សារនោះឯងមិញ
កុំឆ្ងល់ឱ្យខ្វល់កើតទុក្ខម្ទេញ　　ព្រោះដ្បិតស្រឡាញ់ហើយថ្លែងទុក ។
កុំតែមានប្អូនជាសង្សារ　　ឱ្យព្រួយចិន្ដានៅពុំសុខ
ហើយគិតអាណិតទៅអាពុក　　សុខទុក្ខដូចម្ដេចគាត់មិនបាន ។

ឯរឿងបត្តិជាភរិយា មិនមានទឹកថានឹងផ្ញើប្រាណ
បើឱ្យរៀមស្បថប៉ុន្មានធាន ក៏បានស្បថដែរណា ធីតា ។
បានជាថ្លែងប្រាប់សព្វសេចក្តី មិនមានអាក់អ្វីទេកល្យាណ៍
ព្រោះតែទុកស្នេហ៍ដួងជីវ៉ា ស្មើឯកមាតាពីក្នុងផ្ទៃ ។
រៀមសូមផ្ញើជន្មសូមផ្ញើកាយ មិនស្តាយខ្លាចក្រែងក្តីក្សិណក្ស័យ
នឹកគ្រាកំសត់ពិសម័យ ទុក្ខភ័យរលួយអស់ទាំងខ្លួន ។
ដូចកល់កូនសត្វបាត់មាតា រត់រកព្រឹក្សាគ្រាន់ពឹងពួន
ទំរាំដុះក្រាស់ចាស់ជាប់ចួន នឹងកូនហើរតាមរកមាតា ។
រឿងនេះសូមថ្លៃអាសូរចិត្ត រៀមពិតណាស់ហើយកុំសង្កា
កុំតែមានប្អូនជាសង្ឃារ រៀមមិនយាត្រាមួយថ្ងៃឡើយ ។
ទោះខុសទោះឆ្គងដូចម្តេចមិញ លើកទោសចោលចេញណាថ្លើមអើយ
ទំរាំតែយើងបានដល់ត្រើយ គង់ស្បើយទុក្ខទេណាធីតា ។
រាត្រីស្រងាត់សត្វដេកស្ងៀម ទ្រូងរៀមស្ទើរប្រេះឆេះឧរា
ឮស្នូរសព្ទម៉ោងទួងនាឡិកា ចិន្តាភ្ញាក់នឹករព្វកដល់ ។
ក្តីដែលធ្លាប់វែងតែងមេត្តា ជេដ្ឋាមិនឱ្យមានថ្នាក់ថ្នល់
ចង្អៀតដូចម្តេចគេចកែកល់ ទៅដល់មិនបានខានឡើយនៃ ។

ឥឡូវរៀមរ័កនិត្យនឹង　　ឥតមានទីពឹងពាក់ប្រស្រ័យ
តែងគិតព្រួយចិត្តតែសព្វថ្ងៃ　　ក្រែងមនុស្សចង្រៃវាព្យាបាទ។
ខុសម្ដេចតាមតែមេត្តាផង　　កុំឱ្យរៀមរងទុក្ខដល់ខ្ចាត
ឱ្យមានតែក្ដីទីអនុញ្ញាត　　សង្ខាតនឹងបានដូចប្រាថ្នា ។
ឱះឱកម្មអនិច្ចា　　ទុក្ខវេទនានេះខ្លួនអើយ
កាលណាទើបបានស្បើយ　　នឹងល្ហែល្ហើយក្ដីអំពល់ ។
អំពើធ្វើពីព្រេង　　នោះវាតែងឱ្យកង្វល់
ភ្លេចភ្លាំងស្លុតស្លាំងសល់　　ព្រោះតែកម្មនានាំមក ។
ឱ្យព្រួយចិត្តចំបែង　　ទុក្ខតែងឯងក្រំក្រៀមកក
វេរារិះគន់គិតរក　　ពុំបានដូចក្ដីប្រាថ្នា ។
ពឹងបុណ្យៗពុំជួយជូន　　កម្មមកផ្ជូនផ្ដល់អាត្មា
បើច្នោះតើអ្នកណា　　ជួយដំរង់គង់មេត្រី ។
ឱ្យបានស្រាន្តទុក្ខា　　កុំឱ្យអសារសេចក្ដី
ដ្បិតទល់ទុក្ខណាស់នៃ　　ស្ទើរប្រេះបែកឧរារង ។
អ្នកទាំងឡាយគេក៏មាន　　ទុក្ខក្នុងប្រាណដូចគ្នាហោង
តែគ្រាន់បើបានសាសង　　សាសម្ទេះទៅមកបាន ។

តែខ្លួននេះម្ដេចឡើយ ធ្វើម្ដេចអើយក៏នឹងបាន
ស្រោកស្រោន្តចិត្តគិតឱ្យក្សាន្ត គិតសព្វគ្រប់ថប់ធ្វេសធ្វេ ។
ប្រាសប្រាណប្រែម្ដេចហៅស្គល់ វិវេកចិត្តក្នុងមណ្ឌល
ព្រួយអំពល់ដោយអាល័យ ញ៉ាំរចំប្រប់សព្វសរសៃ ។
ធរណីអាកាសា ឆ្ងាយពីគ្នាគួរណាស់នៃ
ឯខ្លួនរៀមនឹងប្អូនថ្លៃ កើតនៅដីផែនពសុធា ។
ក្នុងជម្ពូទ្វីបបរលោកិយ រាជបុរីកម្ពុជា
យើងទាំងពីរបានស្គាល់គ្នា គួរអ្វីឆ្ងាយសល់សែនទ្វី ។
ពឹងថ្ងោល ៗ នោះរសាត់ អណ្ដែតបាត់ចេញទីទៃ
ចង្កូតភ្លាត់ចេញពីដៃ សំពៅធ្លាយធ្លុះអសារ ។
ទ្វេម៉ោងពីរប្រា កងកើតក្ដួចករ
ភាន់ភាំងក្នុងហ- ទ័យទៀងវិចារណ៍
ពឹងពីសាន្តសា បាយបិតឃ្លាតអា
ល័យលុះសូន្យសោះ ។

ពីរអង្គនៃបនៅ ឥឡូវបែរបោះ
តែខ្លួនមួយសោះ ឥតគូប្រណី ។

លុះម៉ោងបីបរិ- បូណ៌គួរសាទរ
ស្តាប់តូរ្យតន្ត្រី រួតរឹងស្រណោះ
ផ្លាប់មូលមេត្រី អាឡោះច្រើនក្តី
មិនដែលឃ្លាតឃ្លា ។

លុះម៉ោងបួនបាន ចរចូលក្នុងឋាន
ប្រាសប្រាណនិទ្រា សែនចន្ទ្រស្វាងជ្រះ
ស្រឡះមេឃា ក្នុងពេលបឋមា
យាមយប់យូរប្រែ ។
ម៉ោងប្រាំប្រាកដ គិតកាលកំសត់
សង្សារស្នាលស្នេហ៍ ឥឡូវដោះដៃ
ទីទៃប្រាសប្រែ គិតសព្វគួរតែ
កុំឈឺគួរកាត់ ។
ជួបចូលពេលា មជ្ឈិមយាមា
អធ្រាត្រស្រងាត់ ម៉ោងប្រាំមួយយប់
ស្ងប់ស្ងាត់សៀងសត្វ ព្រះពាយផាយផាត់

រំភើយវ៉ាតា ។

បក់តាមបង្អួច ភ្ញាភ្ញាក់ព្រឺព្រួច
ប្រាណប្រែកាយា បែរឆ្វេងឃើញគេ
ទៀតទេជាគ្នា បែរស្តាំឯកអា-

នាថោធុថប់ ។

លុះដល់ម៉ោងប្រាំ- ពីរពេលរះកាំ
រង្សៀសចិត្តថប់ សល់សែនសង្វេគ
អស់អែកគិតគ្រប់ រំលែកចិត្តសព្វ

សេចក្តីអនិច្ចា ។

ដល់ម៉ោងប្រាំបី ស្រងាត់រាត្រី
រស្មីចន្ទ្រា រសៀលទាបទៅ
ទិសបច្ចិមា ដង្ហែតារា

ទន់ៗទៅហើយ ។

ដាស់ទុំស្រងាត់ ម៉ោងប្រាំបួនថ្វាត់
ភីរីទ្ទូងឆ្លើយ សកុណាភ្ញាក់តាម
ពេលយាមយប់ហើយ យាយយំឆ្លុះឆ្លើយ

សូរល្វើយសានសំ ។

លុះដល់ម៉ោងដប់ ញ័រខ្លួនចំប្រប់
ដូចគេវាយដំ សំសូរសៀងសត្វ
មាត់មាន់រងំ រងាវស៊ានសំ

ឡេងឮក្រលួច ។

ស្ដាប់ជាក់ហើយណា ណែនក្នុងឱរា
ចិន្ដាព្រឺព្រួច ប្អូកប៉ីសប្អើសប្អៀង
មើលមៀងដាលដូច កកើតកាន់ក្ដួច

គន់គិតអនិច្ចា ។

នក្សត្រប្ញក្សរះ ពីទិសបូពា
នៃបនៅតារា ពិតពុំឃ្លាតឃ្លា
ទន្ទឹមទាំងគូ ..................

................ ។

សូរស័ព្ទសៀងសៃ ចចាតប្រឡៃ
ច្រឡំមយូរ ភុមរីយាសយំ
រងំរកគូ អកអាអួតភួ

មាត់មាន់ទោទ្បេវ ។

ដេកដោយហ្វូងវា ភ្ញាក់ឡើងហើយណា
យាសយំទ្រូសទ្រេវ សេកសត្វសារិកា
ទទាស្រែកស្រេវ តាវៅកញ្ច្រេវ
បន្ទុយស័ព្ទវា ។

យំទ្បើនទិនករ ឆ្លើយរឿយឆ្លើយរ-
ងំសំបក្សា មាន់រងាវកុះ
ស្រែកស្រុះកាន់គ្នា ស្រណោះពេលា
ពេលនោះណាស់ណា ។

លុះម៉ោងមួយដន់ ដប់កាលអរុណ
ទ្បេបស្វាងសុរិយា នរាធបក្ស
បច្ចូសម័យ ។

សព្វសត្វគ្រៀងគេ រះឥតរះអែ
ស្មាលស្នែហ៍មូលមៃ ត្រីត្រេកបៃតី
បែកតាំងក្រេមក្សាន្ត ។

ឯកអង្គទាការ នឹករកនរណា

នៅផងសោះគ្មាន　　　មានតែអង្គឯង
គួរឈ្មោងអាធ្យាន　　　អាធ្យោកកំសាន្ត
កុំសោយទុក្ខពេក ។

លុះដល់ម៉ោងពីរ　　　ដណ្តប់ភុម្រី
ទូរទ្វូងព្យ៊ាន　　　អ្នកងារតែងកាន់
នោះនៅកំណាន់　　　ទ្វងចាំរាជវាំង
មិនដែលឆ្លូកឆ្លះ ។

ព្រហាមព្រិលព្រិម　　　ព្រលិមថែងច្បាស់
ព្រះអាទិត្យរះ　　　លេចលើក្បែរក្បាំង ។
គិរីបរិពតា　　　ប្រាកដថែងចាំង
ភ្លឺផ្លេកបូពិទាំង　　　សាកលភារា ។៚

# ចប់

# ច្បាប់រាជនេតិ

កុំជឿងដោយខ្យល់ កុំឱ្យពាក្យពល់
កុំខ្វល់ដោយស្រី កុំកាន់ពិសយង់
គប់នឹងស្ត្រី សមណជនជី
កុំផ្ដិតត្រូវ ។

(ព្រះរាជនិពន្ធ ព្រះស្រីធម្មរាជា រាជសម្ភារ)

